# សេចក្តីប្រកាសព័ត៌មានរបស់ ម.ស.ម.ក
# ប្រធានសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា និងបុគ្គលិករបស់ខ្លួនពីររូបត្រូវបានចាប់ខ្លួន នៅខេត្តក្រចេះ

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២៣

| | |
|---|---|
| កាលបរិច្ឆេទនៃហេតុការណ៍៖ | ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ |
| ប្រភេទអ្នកការពារសិទ្ធិមនុស្ស៖ | សកម្មជនសិទ្ធិមនុស្ស |
| ទីកន្លែង៖ | ខេត្តក្រចេះ និងខេត្តរតនគិរី |
| ប្រភេទនៃការគំរាមកំហែង៖ | សេរីភាពខាងសមាគម |

កាលពីរសៀលថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣ នគរបាលខេត្តក្រចេះបានបញ្ឈប់ និងឃាត់ខ្លួនបុគ្គលិកសមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជា («សមាគម») ចំនួន១៧នាក់យកទៅសាកសួរនៅស្នងការដ្ឋាននគរបាលខេត្ត។ នគរបាលក៏បានឃាត់ខ្លួនសមាជិកគ្រួសាររបស់ពួកគេចំនួន៣២នាក់ផ្សេងទៀតរួមទាំងកុមារផងដែរ។ ការឃាត់ខ្លួននេះធ្វើឡើង ខណៈពួកគេកំពុងធ្វើដំណើរពីខេត្តរតនគិរី ទៅកាន់រាជធានីភ្នំពេញ បន្ទាប់ពីចូលរួមសិក្ខាសាលាពង្រឹងសមត្ថភាព និងកិច្ចប្រជុំឆ្លុះបញ្ចាំងបុគ្គលិករបស់ខ្លួនចាប់ពីថ្ងៃទី១៣ ដល់១៤ ខែឧសភា ឆ្នាំ២០២៣។

បុគ្គលិកសមាគម០៣នាក់រួមមាន លោក ថេង សាវឿន ដែលជាប្រធានសមាគម លោក ញ៉ិល ភាព មន្ត្រីជាន់ខ្ពស់ផ្នែកចងក្រង និងតស៊ូមតិ និងលោក ថាន់ ហាច មន្ត្រីសម្របសម្រួលសហគមន៍ ត្រូវបានឃាត់ខ្លួនពេញមួយយប់ មុនពេលបញ្ជូនទៅកាន់ស្នងការនគរបាលខេត្តរតនគិរីដើម្បីសាកសួរបន្ថែមនៅថ្ងៃទី១៨ ខែឧសភា។ បុគ្គលិកសមាគមចំនួនស១៤នាក់ និងសាច់ញាតិរបស់ពួកគេចំនួន៣២នាក់ផ្សេងទៀតត្រូវបានដោះលែង និងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះវិញនៅថ្ងៃទី១៧ ខែឧសភា នោះ។ អាជ្ញាធរបានរឹបអូសយកកុំព្យូទ័រ ទូរស័ព្ទដៃរបស់បុគ្គលិក ក៏ដូចជាឯកសារមួយចំនួនរបស់សមាគមផងដែរ។

អ្នកទាំងបីនាក់ត្រូវបាននគរបាលខេត្តរតនគិរីសាកសួររហូតដល់រសៀលថ្ងៃទី២០ ខែឧសភា ទើបបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការបន្ត។ អ្នកទាំងបីមិនត្រូវបានអនុញ្ញាតឱ្យមានតំណាងផ្នែកច្បាប់នោះឡើយ មុនពេលមេធាវីរបស់ពួកគេត្រូវបានអនុញ្ញាតឱ្យការពារអ្នកទាំងបីក្នុងដំណាក់កាលសួរចម្លើយរបស់តំណាងអយ្យការ

នៅថ្ងៃទី២២ ខែឧសភា។ ពួកគេក៏ត្រូវបានអនុញ្ញាតឱ្យជួបជាមួយក្រុមគ្រួសាររបស់ខ្លួនរយៈពេលខ្លីផងដែរ។ អ្នកទាំងបីត្រូវបានចោទប្រកាន់ពីបទរួមគំនិតក្បត់ និងញុះញង់ តាមមាត្រា៤៥៣ មាត្រា៤៩៤ និងមាត្រា៤៩៥ នៃក្រមព្រហ្មទណ្ឌ និងបញ្ជូនទៅឃុំខ្លួនបណ្ដោះអាសន្ននៅពន្ធនាគារខេត្តរតនគិរី។ ប្រសិនបើរកឃើញថាមានទោស ពួកគេអាចនឹងប្រឈមការជាប់ពន្ធនាគាររហូតដល់១០ឆ្នាំ និងពិន័យជាប្រាក់ចំនួនបួនលានរៀល។

ជាមួយគ្នានេះ នៅរាជធានីភ្នំពេញ កសិករ និងសមាជិកសហគមន៍ប្រមាណ១៥០នាក់ មកពីបណ្ដាខេត្តផ្សេងៗ រួមទាំងម្ដាយបង្កើតរបស់លោក ថេង សាវឿន ផងនោះ បានដង្ហែក្បួនចេញពីវត្តសាមគ្គីរង្សី (ក្នុងខណ្ឌមានជ័យ រាជធានីភ្នំពេញ) ឆ្ពោះទៅក្រសួងមហាផ្ទៃ ដើម្បីទាមទារឱ្យដោះលែងអ្នកទាំងបី។ តំណាងសហគមន៍ចំនួន១០នាក់ត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងក្រសួងដើម្បីពន្យល់អំពីគោលបំណងនៃការជួបជុំដោយសន្តិវិធី និងការទាមទាររបស់ខ្លួន។ មន្ត្រីរបស់ក្រសួងបានស្នើសុំឱ្យពួកគេរង់ចាំដំណោះស្រាយ និងរំសាយការប្រមូលផ្ដុំនៅពេលល្ងាច។ នៅបរិវេណខាងក្រៅក្រសួង មានអាជ្ញាធរខណ្ឌចំការមន និងនគរបាលក្នុងឯកសណ្ឋាន និងស៊ីវិល បានមកឃ្លាំមើល ព្រមទាំងថតរូបអ្នកប្រមូលផ្ដុំយ៉ាងជិតដល់ផងដែរ។ នៅថ្ងៃទី២៣ ខែឧសភា នេះ បាតុករបានមកប្រមូលផ្ដុំគ្នាម្ដងទៀត។ នៅថ្ងៃដដែលនេះ ពន្ធនាគារខេត្តរតនគិរីបានហាមសមាជិកគ្រួសារមិនឱ្យសួរសុខទុក្ខបុគ្គលិកសមាគមដែលជាប់ឃុំ ដោយអះអាងថាអ្នកទាំងបីត្រូវតែធ្វើចត្តាឡីស័ក្កជំងឺកូវីដ១៩ រយៈពេល១៤ថ្ងៃជាមុនសិន។ ទោះជាយ៉ាងនេះក៏ដោយ ពួកគេត្រូវបានអនុញ្ញាតឱ្យផ្ញើអាហារដល់សាច់ញាតិរបស់ខ្លួនផងដែរ។

សមាគមសម្ព័ន្ធសហគមន៍កសិករកម្ពុជាគឺជាអង្គការសមាជិកភាព ត្រូវបានបង្កើតឡើងនៅខែមករា ឆ្នាំ២០១១ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងសិទ្ធិដីធ្លី ធនធានធម្មជាតិ និងការបណ្ដេញចេញដោយបង្ខំដែលកើតចេញពីគម្រោងអភិវឌ្ឍន៍ និងកសិករដែលរងផលប៉ះពាល់នៅក្នុងប្រទេសកម្ពុជា។ លោក ថេង សាវឿន ធ្លាប់ត្រូវបានចាប់ខ្លួន និងដាក់ពន្ធនាគារជាមួយនឹងបុគ្គលិកអង្គការក្រៅរដ្ឋាភិបាល កម្មកររោងចក្រកាត់ដេរ និងសមាជិកសហគមន៍ផ្សេងទៀតកាលពីខែមករា ឆ្នាំ២០១៤ បន្ទាប់ពីមានការបង្ក្រាបដោយហិង្សាលើបាតុករនៅរាជធានីភ្នំពេញ។ លោកត្រូវបានជាប់ពន្ធនាគារបណ្ដោះអាសន្នរយៈពេលប្រាំខែ មុននឹងត្រូវបានកាត់ទោសឱ្យជាប់ពន្ធនាគាររយៈពេលបួនឆ្នាំ ដោយទោសទាំងអស់ត្រូវព្យួរ។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកផ្នែកតស៊ូមតិ នៃ ម.ស.ម.ក តាមរយៈទូរស័ព្ទ៖ +៨៥៥ (០) ៨៨ ៨១៤ ២៧៨៣ ឬអ៊ីម៉ែល៖** yuthyia@cchrcambodia.org ។